ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ :...០៧០៤......ន.ទ.ក.

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី**

**ប្រធានក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត អចល័ត និង អ៊ិនធឺណិតទាំងអស់**

**កម្មវត្ថុ ៖** ស្តីពីកាតព្វកិច្ចផ្សព្វផ្សាយតាមប្រព័ន្ធទូរគមនាគមន៍នូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធការបញ្ជាក់អត្តសញ្ញាណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាគ្រឹះស្ថានឯកជន ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ និយ័តករទូរគមនាគមន៍កម្ពុជា សូមជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត អចល័ត និង អ៊ិនធឺណិតទាំងអស់ ជ្រាបថា៖ ស្របតាមការឯកភាពនៅក្នុងកិច្ចប្រជុំនារសៀលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ នៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បណ្តាក្រុមហ៊ុនទាំងអស់ត្រូវចូលរួមសហការផ្សព្វផ្សាយអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធការបញ្ជាក់អត្តសញ្ញាណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាគ្រឹះស្ថានឯកជន ។

ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់តាមអនុសាសន៍របស់ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា និយ័តករទូរគមនាគមន៍កម្ពុជា សូមណែនាំដល់បណ្តាក្រុមហ៊ុនទាំងអស់ចាត់ចែងការងារដូចខាងក្រោម៖

**ក) សម្រាប់ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត និង អចល័ត**

- ត្រូវរៀបចំដំណើរការប្រព័ន្ធ Call Ring Back Tone (CRBT) នៅក្នុងបមាណីរបស់ក្រុមហ៊ុនសម្រាប់គ្រប់អ្នកប្រើប្រាស់ទូរស័ព្ទចល័ត និង អចល័តទាំងអស់ ដោយប្រើប្រាស់សារសំឡេងអប់រំ « *គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជា ជារបស់ឯកជន មិនមែនជារបស់រដ្ឋនោះទេ សូមបងប្អូនប្រជាពលរដ្ឋកុំយល់ច្រឡំ* » ជំនួសឱ្យសំឡេងរោទិ៍ធម្មតា ឬ បទចម្រៀងនៅគ្រប់ពេលហៅទូរស័ព្ទចេញ ។
- ត្រូវផ្សព្វផ្សាយខ្លឹមសារអប់រំខាងលើ តាមរយៈសេវាសារខ្លី (SMS) ទៅកាន់អ្នកប្រើប្រាស់សេវាទូរស័ព្ទចល័តទាំងអស់ដោយឥតរើសអើង ឱ្យបានជារៀងរាល់ថ្ងៃ ។

**ខ) សម្រាប់ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត អចល័ត និង អ៊ិនធឺណិត**

- ត្រូវបង្ហោះ និង រត់អក្សរជាខ្លឹមសារអប់រំ « *គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជា ជារបស់ឯកជន មិនមែនជារបស់រដ្ឋនោះទេ សូមបងប្អូនប្រជាពលរដ្ឋកុំយល់ច្រឡំ* » នៅក្នុងផ្នែកខាងលើបង្អស់នៃគេហទំព័រដំបូង (Homepage) របស់ក្រុមហ៊ុននីមួយៗ ។
- ត្រូវចូលរួមផ្សព្វផ្សាយ និង បង្ហោះខ្លឹមសារអប់រំខាងលើ នៅក្នុងទំព័រ (Page) Facebook ផ្លូវការ និងតាមគ្រប់មធ្យោបាយបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT) ទាំងអស់របស់ក្រុមហ៊ុននីមួយៗ ឱ្យបានទៀងទាត់ និងបន្តបន្ទាប់។


វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
(855) 23 72 23 33
(855) 23 72 32 22
info@trc.gov.kh
www.trc.gov.kh

ទន្ទឹមនឹងនេះ ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និយ័តករទូរគមនាគមន៍កម្ពុជា ក៏សូមជម្រាបជូនថា៖ ក្រុមហ៊ុនទាំងអស់ត្រូវចូលរួមអនុវត្តការណែនាំខាងលើ **រយៈពេល ០១ (មួយ)** ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខានៃលិខិតនេះជាកំហិត ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត អចល័ត និង អ៊ិនធឺណិតទាំងអស់ ជ្រាប និងអនុវត្តតាមខ្លឹមសារនៃលិខិតនេះដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រីប្រធានក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័ត អចល័ត និង អ៊ិនធឺណិតទាំងអស់ទទួលនូវការរាប់អានអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧

**ប្រធាន**

**ម៉ុង ចរិយា**

**ចម្លងជូន៖**

-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

*"ដើម្បីជូនជ្រាប"*

-ឯកសារ-កាលប្បវត្តិ